Thouen / 2002

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ១៥៩ បទ.ប្រក

ភ្នំពេញ, ថ្ងៃទី ០៧ ខែ ០៦ ឆ្នាំ ២០០២

## ប្រកាស

## ស្តីពីការបង្កើតគណកម្មការត្រួតពិនិត្យចំណូលចំណាយ អាជីវកម្ម សេវាកម្ម នៃមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ទូទាំងខេត្ត-ក្រុង

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-អនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញការងារចាំបាច់របស់ក្រសួង

### សំ រេ ច

ប្រការ ១ : ត្រូវបានបង្កើតគណកម្មការមួយរបស់ក្រសួង ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-លោក | គ្រី នេង | ប្រធានធកិការដ្ឋាន | ប្រធាន |
| ២-លោក | កែវ ឧត្តរិន | អនុប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣-លោក | ឆេង ម៉ុន្នា | ប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ៤-លោក | សរ រតនា | អនុប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ៥-លោក | ឡាយ គ្នុក | អនុប្រធានការិយាល័យហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក | ហេង គា | អនុប្រធានការិយាល័យអធិការកិច្ច | សមាជិក |
| ៧-លោក | ស៊ីន ម៉េងហោ | អនុប្រធានការិយាល័យអធិការកិច្ច | សមាជិក |

**ប្រការ ២ :** គណកម្មការនេះ មានភារកិច្ច ត្រួតពិនិត្យរាល់ការចំណូលចំណាយអាជីវកម្ម សេវាកម្ម លើវិស័យប្រៃសណីយ៍ និង ទូរគមនាគមន៍ និងធ្វើការណែនាំពីនីតិវិធីការងារគណនេយ្យ-ហិរញ្ញវត្ថុ តាមបណ្តាមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ទូទាំងខេត្ត-ក្រុង ។ ក្រោយពេលចប់ភារកិច្ចត្រូវរាយការណ៍លទ្ធផលការងារជូន ឯកឧត្តម រដ្ឋមន្ត្រី ដើម្បីពិនិត្យ និង សុំយោបល់សំរេច ។

**ប្រការ ៣ :** រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** ខុទ្ទកាល័យ-ធអិការដ្ឋាន-នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ-គ្រប់មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ទូទាំង ខេត្ត-ក្រុង និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

សូ ខុន

**<u>កន្លែងទទួល</u>**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៤ " ដើម្បីអនុវត្តន៍ "
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ